**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈបញ្ជាការដឹកនាំបញ្ជា**
**ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក**

លេខ ៖ ០៧៣ សណន/គបចគ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៩

## សេចក្តីណែនាំ
## ស្តីពីវិធានការលុបបំបាត់ការកែច្នៃតម្លើងយានយន្តខុសបទដ្ឋានបច្ចេកទេស

- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស /រកម /០២០៧ /០០៧ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៧
- អនុក្រឹត្យលេខ១៨០ អនក្រ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រង យានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃតម្លើងយានយន្ត
- អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណា ចក្រកម្ពុជា ថ្លែងនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩

កន្លងមក មានយានយន្តដឹកជញ្ជូនទំនិញ ដឹកអ្នកដំណើរ និងដឹកប្រេងឥន្ធនៈមួយចំនួន បានកែច្នៃតម្លើង តថែមបណ្តោយ ឬកំពស់ទ្រុង បន្ថែមភ្លៅ បន្ថែមកៅអី បន្ថែមដំបូល ហើយបានផ្ទុកទំនិញ ប្រេងឥន្ធនៈឬដឹកអ្នកដំណើរលើសកំរិតកំណត់មិនសមាមាត្រទៅនឹងកម្លាំងម៉ាស៊ីន កម្លាំងហ្វ្រាំង និងប្រព័ន្ធបច្ចេកទេសផ្សេងៗទៀត ជាហេតុបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍និងការខូចខាតផ្លូវថ្នល់ក្នុងកំរិតធ្ងន់ធ្ងរ ។

ដើម្បីទប់ស្កាត់ និងលុបបំបាត់បាតុភាពទាំងនេះ គណៈបញ្ជាការដឹកនាំបញ្ជាត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកណែនាំដល់គណៈបញ្ជាការដឹកនាំបញ្ជាត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោករាជធានី-ខេត្ត ត្រូវជំរុញមន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធចាត់វិធានការម៉ឺងម៉ាត់ ដូចខាងក្រោម៖

- ត្រូវបង្កើនការអប់រំណែនាំដល់ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូន ម្ចាស់យានដ្ឋាន និងម្ចាស់យានយន្តដឹកជញ្ជូនគ្រប់ប្រភេទត្រូវតែអនុវត្តន៍ម៉ឺងម៉ាត់តាមមាត្រា៥២ ៥៣ និង ៥៤ នៃច្បាប់ចរាចរណ៍ផ្លូវគោក និងអនុក្រឹត្យលេខ ១៨០ អនក្រ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ។
- ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូន ម្ចាស់យានដ្ឋាន និងម្ចាស់យានយន្តដឹកជញ្ជូនទាំងឡាយណា បានកែច្នៃយានយន្តផ្ទុយពីការកំណត់ដែលមានចែងក្នុងច្បាប់ចរាចរណ៍ផ្លូវគោក និងអនុក្រឹត្យលេខ ១៨០ អនក្រ ត្រូវធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវមិនឱ្យហួសថ្ងៃទី០៩ ខែ តុលា ឆ្នាំ ២០០៩ ។
- ចាប់ពីថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៩ តទៅក្នុងករណីរកឃើញរូបវន្តបុគ្គល ឬនីតិបុគ្គលណា ប្រព្រឹត្តល្មើស ត្រូវបង្ខំឱ្យកែតម្រូវយានយន្តស្របតាមច្បាប់ ដកហូតលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ពិន័យ និង/ឬ ធ្វើកំណត់ហេតុបញ្ជូនទៅតុលាការ ។

ទទួលបានសេចក្តីណែនាំនេះ គណៈបញ្ជាការដឹកនាំបញ្ជាត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោករាជធានី-ខេត្ត ត្រូវចាត់តាំងអនុវត្តន៍ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព ។

**ជ. គណៈបញ្ជាការដឹកនាំបញ្ជា**
**ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក**
**ប្រធាន**

**ស ខេង**

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ